ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿងលេខៈ១៥៨
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩

**<u>សាលដីកា</u>**

លេខៈ១៧
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឌឹត មុន្នី** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **រៀល មួន** ជាចៅក្រម
៤-លោក **ជីវ កេង** ជាចៅក្រម
៥-លោក **ស៊ិន ឌឹម** ជាចៅក្រម
៦-លោក **ឈឹម ស៊ីផល** ជាចៅក្រម
៧-លោក **សោម សិរីវឌ្ឍ** ជាចៅក្រមរបាយការណ៍
៨-លោក **ប្រាក់ គឹមសាន** ជាចៅក្រម
៩-លោក **យស់ សូខឿន** ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក **សុង ម៉ៅ**

**<u>តំណាងមហាអយ្យការ</u>**

-លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៤៥៥ ចុះថ្ងៃទី១៩ ខែសីហាឆ្នាំ ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៥០ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់សាលា ឧទ្ធរណ៍ ។

-រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះទួន ផង់ ភេទប្រុស អាយុ៦៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិកំប៉ាល ឃុំសណ្តែក ស្រុកបាជាយ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះតូច ទួន(ស) ម្តាយឈ្មោះចាន់ ជីម (ស) ប្រពន្ធ ឃី អ៊ាង ។

-រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះជៀម ដុន ភេទប្រុសអាយុ៩៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិកំប៉ាល ឃុំសណ្តែក ស្រុកបាជាយ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ស៊ាន់ ជៀម (ស) ម្តាយឈ្មោះអ៊ូ សុំ (ស) ប្រពន្ធឈ្មោះ សុំ ណឹប ។

-និងចុងបណ្ដឹងសាទុក្ខឈ្មោះសោម ប៉ាត ភេទប្រុស អាយុ៧០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិតាព្រង ឃុំគ្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម ។ឪពុកឈ្មោះ សោម វង្ឃ (ស) ម្ដាយឈ្មោះតុប សេង (ស) ។

**កម្មវត្ថុបណ្ដឹង:** ប្ដឹងសុំសិទ្ធិគ្រប់គ្រងដីស្រែប្រាំង១០០ម៉ែត្រ គុណ ២៥០ម៉ែត្រ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៧៣ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ១៩៩៩ របស់ឈ្មោះទូន ផង់ និងលោកជៀម ជុន ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៤៥៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៥៨ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ របស់ តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៧.០៣.៩៦ របស់ឈ្មោះលោកជៀម ជុន និងលោកទូន ផង់ ប្ដឹងទាមទារដីស្រែប្រាំងទំហំ១០០ម៉ែត្រ គុណ ២៥០ម៉ែត្រ ជាកម្មសិទ្ធិដោយហេតុថាដីនេះខ្លួនទាំង២នាក់បានកាន់កាប់ និងគ្រប់គ្រងពីឆ្នាំ១៩៨៩ មកទល់ឆ្នាំ១៩៩៥ ស្រាប់តែឈ្មោះសោម ប៉ាត បានមកទាមទារដីនោះ ថាជា ដីកេរ្ដិ៍របស់គាត់ពីសង្គមចាស់ ដោយឈ្មោះសោម ប៉ាត បានយកត្រាក់ទ័រមកភ្ជួរដីស្រែរបស់ខ្លួនទាំង២។ រដ្ឋអំណាចស្រុកបានដោះស្រាយប្រគល់ដីនោះឱ្យខ្លួននៅថ្ងៃទី២៨-០៨-១៩៩៥ តែឈ្មោះនេះពុំព្រមប្រគល់ឱ្យ។

បានឃើញសាលក្រមរដ្ឋប្បវេណីរបៀបលេខ១៣៤(ក) ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.អង្កេតសួរចម្លើយឈ្មោះចិន ជន មួង មិន និងឈ្មោះសាយ នាង ព្រមទាំងរកលិខិតដើមដែលអ្នកទាំងបីបានចុះហត្ថលេខា ។

២- ក្រោយពេលស៊ើបសួររួចហើយ ទើបតុលាការលើកយករឿងនេះមកជំនុំជំរះឡើងវិញ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៧០(ក) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះទូន ផង់ និងជៀម ជុន ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ១៩៩៦ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលសិទ្ធិរបស់ដើមចោទឈ្មោះទូន ផង់ និងជៀម ជុន ជាសប្បទានិក លើដីកើតហេតុចាប់ពីពេលដែលសាលក្រមនេះចូលជាស្ថាពរនៅពេលនោះឈ្មោះសោម ប៉ាត ត្រូវប្រគល់ដីនេះមកឱ្យដើមចោទបង្កបង្កើតផលដូចដើមវិញ តាមមាត្រា២នៃច្បាប់ភូមិបាល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដី៧.០០០រៀល ដែលដើមចោទបានបង់ទុករួច ។ នៅពេល សាលក្រមចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយបង់សងទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ

មួយភាគរយលើតម្លៃដី១.៣០០.០០០រៀល គឺ $\frac{១x១.៣០០.០០០}{១០០}$ =១៣.០០០រៀល ប្រាក់នេះត្រូវកាត់ចូលជាថវិការដ្ឋចំនួន២០%គឺ $\frac{៨០x១.៣០០.០០០}{១០០}$ =១០.៦០០រៀល និងត្រូវបានសម្រាប់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជាចំនួន២០%គឺ $\frac{២០x១៣.០០០}{១០០}$ =២៦០០រៀល នៅពេលសាលក្រមចូលជាស្ថាពរបង្គាប់ឱ្យដើមចោទ បង់ទុកជាមុនទើបបង្គាប់ឱ្យចុងចម្លើយបង់សងជាក្រោយ ។

៤- សាលក្រមនេះ ប្រកាសជាសាធារណៈ នៅចំពោះមុខដើមចោទ និងចុងចម្លើយ ភាគីណាមិនសុខចិត្តនិងសាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៦ របស់ឈ្មោះសោម ប៉ាត មិនសុខចិត្តសាលក្រមរដ្ឋប្បវេណីលេខ១៧០(ក) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ចាមត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៥៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ នៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះសោម ប៉ាត ចុះថ្ងៃទី១១-០៩-៩៦ ទុកជាត្រឹមត្រូវ តាមទម្រង់និងគតិច្បាប់ ។

២-បដិសេធសាលក្រមលេខ១៧០(ក) ចុះថ្ងៃទី១១-០៩-៩៦ របស់តុលាការខេត្តកំពង់ចាមចោលជាអាសារបង់ ។

៣.ប្រគល់ដីទំនាស់ដែលមានទទឹង បណ្តោយតាមគំនូសប្លង់ ចុះថ្ងៃទី២៣.០៦-៩៦ របស់ប្រធានភូមិបាលស្រុកបាធាយ ទៅឱ្យឈ្មោះសោម ប៉ាត កាន់កាប់តទៅ ។ យោងតាមមាត្រា២.៧៤ ច្បាប់ភូមិបាល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលគឺ ពន្ធចុះបញ្ជីក្តីនិង ពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០រៀលនិងចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។បង្គាប់ឱ្យឈ្មោះទូន ផង់ និងជៀម ជុន បង់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ ។

៥. សាលដីកានេះ ប្រកាសជាសាធារណៈចំពោះដើមបណ្តឹងឧទ្ធរណ៍ និងចុងបណ្តឹងឧទ្ធរណ៍ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១០ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧ របស់លោកទូន ផង់ និងលោកជៀម ជុន លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ៤៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូលសម្រេចចំពោះ មុខលោកទូន ផង់ និងលោកជៀម ជុន កំបាំងមុខលោកសោម ប៉ាត នៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងសាទុក្ខលេខ៣១០ ចុះថ្ងៃទី១៩-០៨-៩៧ របស់ឈ្មោះទូន ផង់ និងឈ្មោះ ជៀម ជុន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៥៥ ចុះថ្ងៃទី១៩-០៨-៩៧ របស់សាលា ឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៨៦ ចុះថ្ងៃទី០៦_១០_៩៧របស់តុលាការកំពូលទៅសាលា ឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលឈ្មោះទូន ផង់ និងឈ្មោះជៀម ជុន បានបង់រួចហើយនៅតុលាការកំពូលគឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្មឹងចំនួន៤០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យឈ្មោះសោម ប៉ាត សងប្រាក់១៩.០០០រៀល នេះទៅឈ្មោះទូន ផង់ និងជៀម ជុន វិញ។

៥-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ៩១ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ១៩៩៩ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលជំនុំជំរះ ដោយសាលដីការដ្ឋប្បវេណីលេខ៤៣ ចុះថ្ងៃទី១៧_០២_៩៨ របស់តុលាការកំពូល បង្វិលរឿងនេះឱ្យសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ ។

តាមមាត្រា១១ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី ។

២-ប្រគល់ដីទាស់ដូចមាននៅក្នុងគំនូសប្លង់បង្ហាញ ចុះថ្ងៃទី២៣-០៦-៩៦ របស់ភូមិបាលស្រុកបាធាយ ឱ្យទៅឈ្មោះសោម ប៉ាត កាន់កាប់ជាកម្មសិទ្ធិ ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរតទៅ ។

៣.សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី សម្រេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៧៣ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ១៩៩៩ របស់លោកទូន ផង់ និងលោកជៀម ជុន ស្ថិតនៅក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពាររបស់ឈ្មោះទូន ផង់ និងលោកជៀម ជុន ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះសោម ប៉ាត ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៩ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ សាលដីការដ្ឋប្បវេណីលេខ៩១ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះទូន ផង់ និងជៀម ជុន ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ បានឆ្លើយថា ៖

+លោកទូន ផង់ ស្រុកនិងខេត្តឱ្យដីនេះមកខ្ញុំតែសាលាឧទ្ធរណ៍មិនឱ្យខ្ញុំទេ ដីនេះចុងចម្លើយ យកធ្វើ៤-៥ឆ្នាំហើយ គេធ្វើពីឆ្នាំ៩៥មក ខ្ញុំកាប់គាស់ធ្វើមុនគេប្រជាជនទីនោះក៏ទៅធ្វើតាមខ្ញុំដែរ ខ្ញុំគ្មានដីណាក្រៅពីដីនេះទេ ។ ពេលតុលាការខេត្ត និងតុលាការកំពូលសម្រេចឱ្យខ្ញុំក៏គាត់មិនព្រម ។

+លោកជៀម ជុន សាលាឧទ្ធរណ៍សម្រេចមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ តុលាការកំពូល សម្រេចត្រឹមត្រូវតាមលក្ខណៈច្បាប់ម្តងហើយ ដីនេះខ្ញុំកាន់កាប់ដោយត្រឹមត្រូវ ។ ពេលខ្ញុំធ្វើតស៊ូណាស់ពេលនោះមានអសន្តិសុខផង ពេលមានរឿងហេតុមេឃុំប្រមូលលិខិតទុកធ្វើឱ្យបាត់តែម្តង ។ ដីខ្ញុំធ្វើពីឆ្នាំ៨៩ ដល់ ៩៥ សោម ប៉ាត យកត្រាក់ទ័រញ្ជួរដីនេះតែម្តង ដោយមានកូនការពារស្រុកសម្រេចឱ្យខ្ញុំ ដូចតុលាការខេត្តដែរ ។ ស្រុក-ខេត្ត ខ្ញុំសុខចិត្តសំរួលបែងចែកតែ សោម ប៉ាតទេដាច់ខាតមិនចែក ។

បានស្តាប់ចម្លើយរបស់ឈ្មោះសោម ប៉ាត ជាចុងចម្លើយបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា ៖ ដីនេះខ្ញុំធ្វើឆ្នាំ៧៩មក មានមេឃុំចែកឱ្យឆ្នាំ៩២ មានដើមចោទមកខ្ចីខ្ញុំធ្វើដោយកូនធ្វើ កងទ័ពខ្ញុំឱ្យធ្វើដល់ឆ្នាំ១៩៩៥យកដីនេះវិញ អ្នកដទៃឱ្យខ្ញុំវិញ តែពីនាក់ជៀម ជុន និងទូន ផង់ មិនឱ្យខ្ញុំទេ ។ ឆ្នាំ១៩៨៩ គ្មានទេ រាជាណាចក្រកម្ពុជា នៅសាធារណៈរដ្ឋកម្ពុជានៅឡើយដីនេះនៅ ភូមិខ្ញុំ ។ សូមតុលាការកំពូល ពិចារណាចុះ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៧៣ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ១៩៩៩ របស់លោកទូន ផង់ និងលោកជៀម ជុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាម មាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ។

-យល់ឃើញថាការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីជាលើកទី២ ដោយសំអាងថាលោកទូន ផង់ និងលោកជៀម ជុន បានខ្ចីដីរបស់លោកសោម ប៉ាត បង្កបង្កើតផលមួយរយៈមានមូលដ្ឋានច្បាស់លាស់នោះ គឺជាការភ័ន្តច្រឡំពីព្រោះថាមានសាក្សី និងរដ្ឋអំណាច ឃុំចាស់បានបញ្ជាក់ថាលោកទូន ផង់ និងលោកជៀម ជុន ពិតជាបានកាន់កាប់ដីទំនាស់តាំងពីឆ្នាំ៨៩ ដល់ឆ្នាំ៩៥ ទើបមានទំនាស់ ហើយមុនឆ្នាំ១៩៨៩ ពុំមានជនណាកាន់កាប់និងបង្កបង្កើតផលលើដីនោះទេ ។

-យល់ឃើញថាលិខិតសុំស្តារដីដែលដើមចោទយកមកសំអាងក្នុងរឿងក្តីនេះពិតជាមានអតិយភាពប្រាកដមែនត្រង់ចំណុចក្បាលលិខិតសរសេរថា រាជាណាចក្រកម្ពុជា និងត្រង់ថ្ងៃខែឆ្នាំ ចុះហត្ថលេខារបស់លោកជិន ជន និងលោក សាយ នាង ថ្វីបើលិខិតសុំស្តារដីនេះមានភាពមិនប្រក្រតីក៏ពិតមែនប៉ុន្តែកិរិយាកាន់កាប់បង្កបង្កើនផលរបស់ដើមចោទ ញុំាងឱ្យលោកមានសិទ្ធិលើដីទំនាស់នេះហើយ ។ ម្យ៉ាងទៀតដោយសារដើមចោទរស់នៅក្នុងឃុំសណ្តែក រីឯចុងចម្លើយ និងដីទំនាស់ស្ថិតនៅក្នុងឃុំត្រប់ដូចគ្នា ហើយដោយដើមចោទ បានយល់ព្រមបែងចែកដីទំនាស់នេះជា៣ ចំណែកស្មើគ្នាហើយនៅមុខតុលាការខេត្តកំពង់ចាមនោះតុលាការគប្បីពិចារណា និងសម្រេចតាម ការយល់ព្រមនេះ ។

-យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ៩១ចុះថ្ងៃទី២៦.០៣.៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៧៣ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ១៩៩៩ របស់លោកទូន ផង់ និងលោកជៀម ជុន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៩១ ចុះថ្ងៃទី២៦.០៣.៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣.បែងចែកដីទំនាស់នេះជា៣ ចំណែកស្មើគ្នាជូនដល់៖

- លោក ទូន ផង់ មួយចំណែក

-លោក ជៀម ជុន មួយចំណែក

-លោក សោម ប៉ាត មួយចំណែក

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោទូន ផង់ បានបង់រួចហើយគឺ ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់លក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោកសោម ប៉ាត សងប្រាក់ចំនួន១៩.០០០រៀល នេះទៅលោកទូន ផង់ វិញ ។

បង្គាប់ឱ្យលោកទូន ផង់ និងលោកជៀម ជុន បង់ពន្ធសមាមាត្រ១%ល្មើ១/៣នៃតម្លៃដីទំនាស់ និងឱ្យលោកសោម ប៉ាត បង់ពន្ធសមាមាត្រលើ២/៣នៃតម្លៃដីទំនាស់ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ ។